# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង

**<u>រវាងក្រុមហ៊ុន យីងសិនសេងព្រីនធីង ឯ.ក និងជាមួយតំណាងកម្មករប្រតិភូបុគ្គលិក</u>**

**<u>និង ប្រធានក្រុម ប្រចាំក្រុមហ៊ុន</u>**

<u>កម្មវត្ថុ</u>៖ កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី ២៥ ខែមិនា ឆ្នាំ ២០២៣ វេលាម៉ោង ២ រសៀល ០០នាទី នៅក្រុមហ៊ុន យីងសិនសេងព្រីនធីង ឯ.ក មានកិច្ចប្រជុំជាមួយ តំណាងក្រុមហ៊ុន និង តំណាង កម្មករនិយោជិត។

នៅអង្គប្រជុំនេះ តំណាងក្រុមហ៊ុនបានជូនដំណឹង ជម្រាបដល់បងប្អូនកម្មករ និយោជិតទាំងអស់គ្នា ស្តីពីស្ថានភាពបច្ចុប្បន្ននៃក្រុមហ៊ុន ដែលខ្វះការបញ្ជារទិញ បណ្តាលអោយក្រុមហ៊ុនយើងបានផ្អាកតំណើរការនៃការផលិត ។

ដូច្នេះក្រុមហ៊ុនបានសម្រេចចិត្ត ព្យួរ កិច្ចសន្យាការងាររបស់កម្មករនិយោជិត ចំនួន០៩នាក់ក្នុងចំណោមកម្មករ ៦៥នាក់ ស្រី ៣៥នាក់ រយៈពេល ២៨ថ្ងៃ ដោយគិតពីថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០២៣ ដល់ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០២៣។

ក្នុងអំឡុងពេលព្យួរកិច្ចសន្យារយៈពេល ២៨ ថ្ងៃ ក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថមចំនួន ៣០ដុល្លារអាម៉េរិច ដោយមានការឯកភាពផងដែរពីប្រតិភូបុគ្គលិក និង កម្មករនិយោជិត ការបើកប្រាក់៣០ដុល្លារអាម៉េរិច ជូនពួកគាត់នៅថ្ងៃទី ២៥ ខែ មេសាឆ្នាំ ២០២៣។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ៣ : ៤៥ នាទី នារសៀលថ្ងៃខែឆ្នាំដដែលប្រកបដោយ បរិយាកាសរីករាយ និងស្និតស្នាល ក្រោមស្មារតី ទទួលខុសត្រូវខ្ពស់និង យោគយល់សហការគ្នាយ៉ាងរលូន។

ថ្ងៃសៅរ៍ ៤ កើត ខែចេត្រ ឆ្នាំខាលចត្វាស័ក ពុទ្ធសករាជ ២៥៦៦

ត្រូវនឹងថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៣

**ស្នាមមេដៃប្រតិភូបុគ្គលិក និយោជិត**

**តំណាងក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
យីង សិន សេង ព្រីនធីង ឯ.ក
KING SEN SHENG PRINTING CO.,LTD.
KINGDOM OF CAMBODIA